ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## ការតាំងពិព័រណ៍ចល័តស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងរបបខ្មែរក្រហម និង កិច្ចសន្ទនាអន្តរជំនាន់នៅខេត្តកោះកុង

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងរៀបចំការតាំងពិព័រណ៍ចល័តលើកទី ៣ ស្តីពី "អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម និងកិច្ចសន្ទនាអន្តរជំនាន់" នៅថ្ងៃទី ២៧-២៨ ខែ មិថុនា នៅសាលមហោស្រព ខេត្តកោះកុង ក្នុងគោលបំណង (១)ផ្តល់ឱកាសឱ្យអ្នកចូលរួមបានដឹងពីរឿងរ៉ាវឈឺចាប់របស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (២) លើកកម្ពស់ការចូលរួមរបស់ជនរងគ្រោះ តាមរយៈការសន្ទនាអន្តរជំនាន់ ដោយផ្តល់ឱកាសឱ្យពួកគាត់បានជួប និងចែករំលែកបទពិសោធន៍ស្តីពីការបង្ខំឱ្យរៀបការក្នុងរបបខ្មែរក្រហមដល់យុវជន (៣) បង្កើនការយល់ដឹងដល់យុវជន និងសាធារណៈជននៅតាមសហគមន៍ឲ្យបានស្វែងយល់បន្ថែមពីអំពើហិង្សាយេនឌ័រក្នុងសម័យខ្មែរក្រហម និងលើកទឹកចិត្តអោយពួកគេចូលរួមប្រឆាំងនឹងអំពើហិង្សាយេនឌ័រនៅសង្គមកម្ពុជានាពេលបច្ចុប្បន្ន និងជម្រុញឱ្យមានសមាណចិត្តដល់ជនរងគ្រោះ។

ព្រឹត្តិការណ៍ថ្ងៃទី១ នឹងចាប់ផ្តើមឡើងទៅនៅវេលាម៉ោង ១:៣០ រសៀល ដល់ម៉ោង ៥ល្ងាច។ អង្គភាពគាំពារជនរងគ្រោះនឹងដាក់តាំងបង្ហាញផ្ទាំងពិព័រណ៍ស្តីពី អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម ហើយមជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណានឹងបញ្ចាំងខ្សែភាពយន្តរឿង "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ" ដោយមានអ្នកទស្សនាប្រមាណ៤០០នាក់ រួមមានជនរងគ្រោះហិង្សាយេនឌ័រ មន្ត្រីរាជការតាមមន្ទីរនានាក្នុងខេត្ត សិស្ស-និស្សិត និងគ្រូបង្រៀន ព្រមទាំងមន្ត្រីអង្គការសង្គមស៊ីវិល។

ព្រឹត្តិការណ៍ថ្ងៃទី២ នឹងចាប់ផ្តើមប្រព្រឹត្តិទៅនៅវេលាម៉ោង ៧:៣០ ព្រឹក ដល់ ម៉ោង១១:៣០ ព្រឹក។ អង្គភាពគាំពារជនរងគ្រោះ នឹងជួបជាមួយនិស្សិតប្រមាណ ១២០ នាក់ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ប្រមាណជា ៣០ នាក់ ដើម្បីពិភាក្សាស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម និងភាពជាប់ពាក់ព័ន្ធទៅនឹងអំពើហិង្សានាពេលបច្ចុប្បន្ន និងស្វែងរកលទ្ធភាពនៃកិច្ចការពារដើម្បីឲ្យមានសុខដុមនីយកម្មសង្គម។

ការតាំងពិព័រណ៍ចល័ត និងកិច្ចសន្ទនាអន្តរជំនាន់ស្ថិតក្រោមគម្រោងក្រៅបច្ចេកទេសតុលាការ "ការលើកកម្ពស់សមភាពយេនឌ័រ និងការធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌របស់អ្នករស់រានមានជីវិតជាស្ត្រី និងជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទក្នុងរបបខ្មែរក្រហម" ដែលទទួលមូលនិធិពីអង្គការសហ

ប្រជាជាតិដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី (United Nations Trust Fund on Violence against Women - UNTF) សម្រាប់ការអនុវត្តក្នុងរយៈពេលបីឆ្នាំចាប់ពីខែមករា ឆ្នាំ២០១៦ ដល់ ខែធ្នូ ឆ្នាំ២០១៨។


**ព័ត៌មានសម្រាប់ធ្វើទំនាក់ទំនងជាមួយអង្គភាពគាំពារជនរងគ្រោះ**

**លោក ហង្ស វណ្ណៈ**

ប្រធានអង្គភាពគាំពារជនរងគ្រោះ នៃអ.វ.ត.ក

ទូរស័ព្ទៈ +៨៥៥ (0) ១៧ ៧៥២៥២០

អ៊ីមែល៖ hang.vannak@eccc.gov.kh